# ជោគជ័យ ហ្វាយនែន

ជម្រើសប្រសើរបំផុតដើម្បីជោគជ័យ






# របាយការណ៍ប្រចាំឆ្នាំ

# ២០២១



# មាតិកា


សាររបស់លោកប្រធានក្រុមប្រឹក្សាភិបាល ........ ២
សាររបស់លោកអគ្គនាយក ........ ៤
អំពីជោគជ័យ
- ប្រវត្តិសង្ខេបរបស់ជោគជ័យ ........ ៧
- ភាគទុនិក ........ ៨
- ចក្ខុវិស័យ បេសកកម្ម វប្បធម៌ និងទស្សនៈវិស័យ ........ ១០
- រចនាសម្ព័ន្ធគ្រឹះស្ថាន ........ ១២
- ក្រុមប្រឹក្សាភិបាល ........ ១៤
- គណៈគ្រប់គ្រង ........ ១៥
- ប្រភពទុនវិនិយោគ និងដៃគូសហការ ........ ២០

សមិទ្ធផលអាជីវកម្មឆ្នាំ ២០២១
- តារាងសង្ខេបលទ្ធផលឆ្នាំ២០២១ ........ ២៣
- ផលិតផលឥណទាន ........ ២៥
- ការិយាល័យសាខាប្រតិបត្តិការ ........ ៣០
- ព្រឹត្តិការណ៍សង្ខេបឆ្នាំ២០២១ ........ ៣៤
- ភាពជោគជ័យរបស់អតិថិជន ........ ៤០

របាយការណ៍ហិរញ្ញវត្ថុ
- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ ៤៣
- របាយការណ៍របស់សវនករឯករាជ្យ ........ ៤៦
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ ៥១
- របាយការណ៍ចំណូលលម្អិត ........ ៥៣
- របាយការណ៍បម្រែបម្រួលមូលធន ........ ៥៤
- របាយការណ៍លំហូរសាច់ប្រាក់ ........ ៥៦

# សាររបស់លោកប្រធានក្រុមប្រឹក្សាភិបាល



**លោក Choi, Moon Kyu**
ប្រធានក្រុមប្រឹក្សាភិបាល

ផ្តើមចេញពីធនធានដ៏រឹងមាំ និង បែបផែនគ្រប់គ្រងពីប្រទេសកូរ៉េខាងត្បូង ជោគជ័យ ហ្វាយនែន បានបង្ហាញវត្តមានគួរឱ្យកត់សម្គាល់ក្នុងនាមជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ **Hanshin Engineering and Construction Co., Ltd** នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ យើងពិតជាមានការភ្ញាក់ផ្អើល និងរីករាយយ៉ាងខ្លាំងចំពោះសមិទ្ធផល និងការខិតខំប្រឹងប្រែងដែលត្រូវបានទទួលស្គាល់ដោយនិយ័តករ ជាពិសេសធនាគារជាតិនៃកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដៃគូសហការនិងសាធារណជន។

អ្វីដែលកាន់ពិសេសជាងនេះទៅទៀត ជោគជ័យ ហ្វាយនែន មានសេចក្តីសោមនស្សរីករាយជាក្រៃលែង ដែលទទួលបានកម្រិតអនុលោមភាពសារពើពន្ធប្រភេទ “មាស” ពីអគ្គនាយកដ្ឋានពន្ធដារ ដែលមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២០ ដល់ ២០២១។ សមិទ្ធផលដ៏ប្រពៃនេះ ទទួលបានមកពីកិច្ចខិតខំប្រឹងប្រែងបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តខ្ពស់ដើម្បីធានាថាយើងបានធ្វើស្របតាមបទប្បញ្ញត្តិពន្ធត្រឹមត្រូវ។

ក្នុងរយៈពេល៥ឆ្នាំមកនេះ ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលខ្ញុំសូមកោតសរសើរដោយស្មោះចំពោះការដឹកនាំរបស់គណៈគ្រប់គ្រងរបស់ជោគជ័យ ដែលបានផ្តល់ទិសដៅច្បាស់លាស់ដល់បុគ្គលិករបស់យើងទោះបីជាស្ថិតក្នុងស្ថានភាពដ៏លំបាកនៃការរីករាតត្បាតជម្ងឺកូវីដ-១៩។ តាមរយៈការដឹកនាំ និងការណែនាំរបស់ពួកគាត់ ទើបធ្វើអោយបុគ្គលិករបស់យើង យល់ដឹងពីរបៀបដោះស្រាយបានយ៉ាងល្អទោះបីស្ថិតក្នុងស្ថានភាពណាក៏ដោយ។

ឆ្នាំ២០២១ បានផ្តល់នូវលំហាត់ជាសកល សម្រាប់មនុស្សគ្រប់ៗគ្នាមិនថាជាបុគ្គល ឬក្រុមហ៊ុនអាជីវកម្មគ្រប់កម្រិត។ យើងពិតជាសំណាងណាស់ ដែលមានគណៈគ្រប់គ្រងដែលចូលរួមយ៉ាងសកម្មក្នុងការត្រិះរិះគិតពិចារណា ដែលតែងតែគិតពីបញ្ហាមុន និងបានរៀបចំយ៉ាងល្អសម្រាប់ដំណោះស្រាយ។

ជំហានដ៏ធំមួយទៀតដែលយើងបានធ្វើ គឺការចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សសម្រាប់ការិយាល័យកណ្តាល និងគ្រប់សាខាទាំងអស់។ រាល់កិច្ចការដែលធ្លាប់ធ្វើដោយដៃពីមុនត្រូវបានធ្វើដោយគ្រាន់តែប្រើប្រាស់នូវម្រាមដៃសម្រាប់ការកត់ត្រាវត្តមាន ការឈប់សម្រាក និងត្រួតពិនិត្យពីបច្ចុប្បន្នភាពព័ត៌មានរបស់បុគ្គលិក។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានបង្ហាញអំពីកំណើនវិជ្ជមានត្រលប់មកវិញប្រហែល ៣% នៅក្នុងឆ្នាំ ២០២១ បន្ទាប់ពីការធ្លាក់ចុះយ៉ាងគំហុក ៣.១% ក្នុងឆ្នាំ២០២០ ហើយតាមរយៈការជួយជ្រោមជ្រែងរបស់រាជរដ្ឋាភិបាល និងផ្នែកផ្សេងទៀត យើងជឿជាក់ថាសេដ្ឋកិច្ច នឹងលូតលាស់ក្នុងរង្វង់ ៥.៦% នៅឆ្នាំ២០២២ យោងតាមការព្យាករណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ទស្សនវិស័យ និងយុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០២២

ផ្អែកលើការវិភាគដ៏វិជ្ជមានពីកម្មវិធីអភិវឌ្ឍន៍អាស៊ី កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើង ៥.៣% ក្នុងឆ្នាំ២០២២ និង ៦.៥% ក្នុងឆ្នាំ២០២៣ អរគុណចំពោះយន្តការនៃការនាំចេញទំនិញដ៏រឹងមាំ ជាមួយនិងលំហូរវិនិយោគផ្ទាល់ពីបរទេស។ ផលិតផលឧស្សាហកម្មត្រូវបានគេរំពឹងថានឹងកើនឡើង ៨.១% ក្នុងឆ្នាំ២០២២ និង ៩.១% នៅឆ្នាំ២០២៣។ ជាមួយគ្នានេះដែរកំណើននេះ នឹងត្រូវបានចូលរួមជំរុញតាមរយៈការអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងទំនិញសម្រាប់ធ្វើដំណើរ ដើម្បីបង្កើនការប្រកួតប្រជែងនៅក្នុងផ្នែកនេះ។ ការនាំចេញទំនិញ និងសេវាកម្មត្រូវបានព្យាករណ៍ថាមានការនឹងកើនឡើងក្នុងឆ្នាំ២០២២ និង២០២៣ តាមរយៈតម្រូវការផលិតផលកម្ពុជាដ៏សម្បើមពីបរទេស ដោយសារការងើបឡើងវិញនៃសេវាកម្មទេសចរណ៍។ វិស័យសេវាកម្មត្រូវបានព្យាករណ៍ថានឹងងើបឡើងវិញ ៤.៨% នៅឆ្នាំ២០២២ និងកើនឡើងដល់ ៦.៨% ក្នុងឆ្នាំ ២០២៣។

ដើម្បីត្រៀមខ្លួន ក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០២២ ជោគជ័យ ប្តេជ្ញាថានឹងបង្កើនឲ្យមានប្រសិទ្ធិភាពជាងមុនទាក់ទង នឹងប្រតិបត្តិការ ដោយដាក់ចេញឲ្យប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ បន្តផ្តល់សេវាកម្មលឿនបំផុត និងបង្កើនអត្ថប្រយោជន៍បន្ថែមដូចអ្វីដែលបានចែងក្នុងពាក្យស្លោករបស់យើងថា "ជម្រើសប្រសើរបំផុតដើម្បីជោគជ័យ"។

ដោយមានការតាំងចិត្តខ្ពស់ក្នុងការឈរនៅលំដាប់កំពូលក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ផ្អែកលើប្រាក់កម្ចី និងកេរ្តិ៍ឈ្មោះល្អ យើងតែងតែស្វែងរកដំណោះស្រាយ ដែលមានប្រសិទ្ធិភាពបំផុតដែលអាចជួយសម្រួលបញ្ហា ឬតម្រូវការរបស់ប្រជាជនកម្ពុជា។ការផ្តោតសំខាន់របស់យើងក្នុងការអភិវឌ្ឍផលិតផល គឺការបន្តពង្រីកវិសាលភាពផលិតផលសេវាកម្មរបស់យើង ពីលក្ខណៈបុគ្គល ទៅលក្ខណៈក្រុមហ៊ុន (អាជីវកម្មទៅអាជីវកម្ម) និងអាចរួមបញ្ចូលទាំងផលិតផលបែបឌីជីថល ឬបច្ចេកវិទ្យាផងដែរ។

អ្វីដែរសំខាន់ផងដែរនោះ ខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់សមាជិកក្រុមប្រឹក្សាភិបាល អគ្គនាយក ថ្នាក់ដឹកនាំកំពូលៗ និងបុគ្គលិកទាំងអស់របស់ ជោគជ័យ ដែលបានចូលរួមយ៉ាងខ្លាំងក្លាដើម្បីសម្រេចនូវសមិទ្ធផលល្អៗ សម្រាប់ក្រុមហ៊ុនរបស់យើង។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់អាជ្ញាធរ អ្នកពាក់ព័ន្ធ អតិថិជន ដៃគូ និងសហគមន៍មូលដ្ឋានសម្រាប់ការជួយសម្របសម្រួលជាប្រចាំក្នុងការជួយឲ្យយើងខិតជិតទៅរកគោលដៅរបស់យើង ក្នុងការកសាងស្ថាប័នហិរញ្ញវត្ថុលំដាប់ពិភពលោក។ ខ្ញុំសូមគោរពនិងថ្លែងអំណរអរគុណចំពោះធនាគារជាតិនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាដែលបានជួយផ្តល់ការណែនាំ និងជួយជ្រោមជ្រែងយ៉ាងស្វាហាប់តាំងពីមុនពេលមានការរីករាលដាលនៃជំងឺរាតត្បាតនេះមកម្ល៉េះ ដើម្បីជំនះស្ថានការណ៍បច្ចុប្បន្ននេះខ្ញុំសង្ឃឹមថានឹងបន្តមានការចូលរួមចំណែកយ៉ាងរឹងមាំ និងប្រកបដោយផ្លែផ្កាពីអ្នកទាំងអស់គ្នាតទៅទៀត។

ដោយក្តីស្មោះត្រង់



**លោក Choi, Moon Kyu**
ប្រធានក្រុមប្រឹក្សាភិបាល

# សាររបស់លោកអគ្គនាយក

ជាង៦ឆ្នាំកន្លងមកនេះ ជោគជ័យ ពិតជាទទួលបានសមិទ្ធផលដ៏គួរឲ្យកត់សម្គាល់យ៉ាងខ្លាំងជាពិសេសបន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណ ជាផ្លូវការពីធនាគារជាតិនៃកម្ពុជា ក្នុងការផ្ទេរកម្មសិទ្ធិពីស្ថាបនិកខ្មែរមកកាន់ម្ចាស់ភាគហ៊ុនជនជាតិកូរ៉េ នៅខែសីហា ឆ្នាំ២០១៧។ គិតត្រឹមខែធ្នូ ឆ្នាំ២០២១ ជោគជ័យបានផ្តល់ឱកាសដល់ធនធានមនុស្សដែលមានសក្តានុពលចំនួន ២៤៩នាក់ ឲ្យចូលបម្រើការនៅទីស្នាក់ការកណ្តាលនិងសាខាប្រតិបត្តិការចំនួន ០៩ ជាមួយនឹងផលប័ត្រប្រាក់កម្ចីជាង ៤៣ លានដុល្លារ និង មានអតិថិជនចំនួន ៥,២០៦នាក់។

ទោះបីជាការផ្ទុះឡើងនៃជម្ងឺកូវីដ-១៩ បានផ្តល់ផលប៉ះពាល់យ៉ាងខ្លាំង ចាប់តាំងពីដើមឆ្នាំ២០២១ យើងនៅតែបន្តមើលឃើញពីកំណើននៃផលប័ត្រប្រាក់កម្ចី នៅក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជាដែលរួមបញ្ចូលគ្នា រវាងគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ (**MFIs**) បានកើនឡើង ២១,២% ប្រមាណ ៤៥,៧ ពាន់លានដុល្លារក្នុងឆ្នាំ២០២១នេះ។



**លោក Park, Cheol Gil**
អគ្គនាយក

ជោគជ័យ ជាផ្នែកមួយនៃភាពរីកចម្រើនបច្ចុប្បន្ននេះសម្រាប់ប្រទេសកម្ពុជាដោយសារតែយើងមានធនធានមនុស្សប្រកបដោយសក្តានុពលខ្ពស់ ជាពិសេសគណៈគ្រប់គ្រងប្រកបដោយគតិបណ្ឌិត ក្រុមការងារផ្នែកប្រតិបត្តិការដ៏សកម្ម និង ក្រុមការងារផ្នែកលក់ពោរពេញដោយសមត្ថភាព។ ពួកគាត់គឺជាចលករដ៏សំខាន់ ក្នុងការចូលរួមចំណែកឥតឈប់ឈរ ដើម្បីសម្រេចគោលដៅស្ថាប័នយើង និងរក្សាភាពប្រកួតប្រជែងនៅក្នុងវិស័យហិរញ្ញវត្ថុ។

អាថ៌កំបាំងនៅពីក្រោយធនធាន ដែលមានសមត្ថភាពរបស់ជោគជ័យ គឺយើងជាជម្រកដែលពោរពេញទៅដោយជំនាញពិតប្រាកដ និងទស្សនៈវិស័យផ្សេងៗគ្នា ដែលធ្វើឲ្យយើងបង្កើតបានគំនិតជាច្រើនប្រកបដោយផ្លែផ្កា។ ការអនុវត្តរបស់យើងគឺ ថែរក្សា និងទាក់ទាញបុគ្គលដែលមានគំនិតច្នៃប្រឌិតខ្ពស់ការប្តេជ្ញា និងជាបុគ្គលដែលសកម្មក្នុងការចូលរួមជួយដោះស្រាយបញ្ហា។អ្វីដែលគួរឲ្យកត់សម្គាល់ផងដែរនោះភាពលេចធ្លោរបស់យើង គឺការផ្តល់ជូនសេវាកម្មរហ័សបំផុត និងការពិគ្រោះយោបល់ផ្នែកហិរញ្ញវត្ថុដោយស្មោះត្រង់ ដើម្បីជួយអតិថិជនបំពេញតម្រូវការទាន់ពេលវេលា និងដើម្បីមនុស្សជាទីស្រលាញ់របស់ពួកគេ។

បញ្ហាប្រឈមដែលមិនអាចដឹងមុនដូចជាជម្ងឺកូវីដ-១៩ និង ការដាក់របាំង នៃផលិតផលនាំចូលមួយចំនួនទៅកាន់ទីផ្សារអឺរ៉ុប" អ្វីៗទាំងអស់លើកលែងតែអាវុធ" បាននាំមកនូវផលប៉ះពាល់មួយចំនួនដល់ប្រទេសកម្ពុជា ជាពិសេសវិស័យទេសចរណ៍ ផលិតកម្មនាំចេញ និងឧស្សាហកម្មសំណង់។ ទោះបីយ៉ាងណាក៏ដោយ ចំពោះបញ្ហាប្រឈមនៃជម្ងឺកូវីដ-១៩ នេះយើងសង្កេតឃើញថារាជរដ្ឋាភិបាលបានចាត់វិធានការបង្ការយ៉ាងតឹងរ៉ឹង និងបានរក្សាទុកនូវឧបករណ៍ពេទ្យមួយចំនួនដើម្បីរួចផុតពីវិបត្តិនេះ។ ជាមួយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ជំនួយសង្គម និង ការគាំទ្រហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម យើងរំពឹងថា កំណើនផលិតផលក្នុងស្រុកសរុបអាចនឹងស្ទុះឡើងដល់ ៥,៦% នៅឆ្នាំ ២០២២។

"គម្រោងផែនការធំបែបផែនណាក៏ដោយអ្វីដែលសំខាន់នោះគឺការចាប់ផ្តើមសកម្មភាពការងារ"។ យើងពិតជាកោតសរសើរយ៉ាងខ្លាំង ចំពោះការផ្លាស់ប្តូរដ៏អស្ចារ្យរបស់យើងក្នុងការទទួលយកប្រព័ន្ធគ្រប់គ្រងធនធានមនុស្សសម្រាប់បុគ្គលិកក្នុងកំឡុងពេលនៃការរក្សាគន្លាតសង្គមនេះ។ នៅឆ្នាំ២០២២ខាងមុខនេះ យើងទន្ទឹងរង់ចាំការបង្កើតនូវផលិតផលសេវាកម្មថ្មីៗ ដែលប្រកបដោយគំនិតច្នៃប្រឌិតខ្ពស់ការបើកដំណើរការជាផ្លូវការនូវកម្មវិធីទូរស័ព្ទដៃរបស់យើង និងកម្មវិធីជួបជុំ និងបង្កើតភាពស្និទ្ធស្នាលសម្រាប់បុគ្គលិក។ ក្នុងនាមជាថ្នាក់ដឹកនាំរបស់ ជោគជ័យ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អតិថិជន និងដៃគូរសហការក្នុងការគាំទ្រ និងជ្រោមជ្រែងយ៉ាងស្អិតរមួតកន្លងមក។

សូមថែរក្សាសុខភាពនិងសុវត្ថិភាពឲ្យបានល្អ!



**លោក Park, Cheol Gil**
អគ្គនាយក

# អំពីជោគជ័យ



## ប្រវត្តិសង្ខេបរបស់ជោគជ័យ



# ភាគទុនិក




ក្រុមហ៊ុន
**Hanshin E&C Co.,ltd**

## ៥១%



ក្រុមហ៊ុន
**Plus International Co.,ltd**

## ៤៩%

# គម្រោងសំណង់ធំៗរបស់ក្រុមហ៊ុន HANSHIN E&C ក្នុងឆ្នាំ ២០២១







# គម្រោងសាងសង់ផ្លូវជាតិលេខ ២ និងផ្លូវជាតិលេខ ៥ ក្នុងប្រទេសកម្ពុជា





ជោគជ័យ ហ្វាយនែន

និមិត្តសញ្ញារបស់ ជោគជ័យ ត្រូវបាន
គូសចេញពី " ទូកប្រណាំងខ្មែរ "

## ចក្ខុវិស័យ

យើងខិតខំប្រឹងប្រែង ដើម្បីក្លាយជាក្រុមហ៊ុនហិរញ្ញវត្ថុលំដាប់ពិភពលោក "**វិសាលភាពលុបលើវិស័យធនាគារ** " ទាំងលើទំហំផលចំណេញ និង " **ការទទួលស្គាល់លើកិត្យានុភាព** " (ភាពជឿជាក់ ភាពងាយស្រួល និងល្បឿននៃសេវាកម្ម) និង " **ការបំពេញចិត្តដល់បុគ្គលិកគ្រប់ជាន់ថ្នាក់** "។

## បេសកកម្ម

**ទទួលបាននូវភក្តីភាពយូរអង្វែងពីសំណាក់អតិថិជន** គោលដៅស្ថិតក្នុងជីវភាពទាប និងមធ្យមតាមរយៈការផ្តល់កម្ចីនិងសេវាកម្មហិរញ្ញវត្ថុដើម្បីជួយលើកកម្ពស់ **អាជីវកម្មប្រកបដោយនិរន្តរភាព** ព្រមទាំងរួមចំណែកបង្កើតនូវ " **វប្បធម៌នៃទម្លាប់ជោគជ័យ** " សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

## វប្បធម៌

ជា **ស្ថាប័នប្រកបដោយសក្តានុពល** យើងមានចក្ខុវិស័យរួមជាសកលដើម្បីប្រែក្លាយជាក្រុមហ៊ុនលំដាប់ថ្នាក់ពិភពលោក ដោយឈរលើមូលដ្ឋាន "**ទម្លាប់នៃការបង្កើតភាពជោគជ័យ**" និងការអភិវឌ្ឍន៍សម្រាប់ "**ការផ្លាស់ប្តូរជាវិជ្ជមាន**"។ យើងទាំងអស់គ្នាប្រឹងប្រែងដើម្បីការរីកចម្រើនរួមគ្នា និងសម្រាប់ជីវិតឯកជនរបស់យើង។ យើងទាំងអស់គ្នាគឺគ្រួសារជោគជ័យ ហ្វាយនែន។

## ទស្សនៈវិស័យ

- ការផ្តល់តម្លៃបុគ្គលិកជាធំ
- ភាពស្មោះត្រង់
- ចេះទទួលយកវប្បធម៌ការងារល្អ
- ការគោរពតួនាទីរៀងខ្លួន
- អព្យាក្រឹតភាព

# រចនាសម្ព័ន្ធគ្រឹះស្ថាន



# ក្រុមប្រឹក្សាភិបាល



### លោក Choi, Moon Kyu
ប្រធានក្រុមប្រឹក្សាភិបាល

- បច្ចុប្បន្នជាអគ្គនាយកក្រុមហ៊ុន Hanshin E&C
- បុគ្គលិកក្រុមហ៊ុន Hyundai Merchant Marine & Hyundai Motor Company
- បរិញ្ញាបត្រពី Sogang University, Seoul, Korea
- បរិញ្ញាបត្រជាន់ខ្ពស់ពី Thunderbird School of Global Management, Arizona, USA



### លោក Kim, Jung Hoon
អភិបាលឯករាជ្យ

- បច្ចុប្បន្នជា នាយកនាយកដ្ឋានហិរញ្ញវត្ថុ ក្រុមហ៊ុន Success Promise Co., Ltd.
- បុគ្គលិកក្រុមហ៊ុន Hyundai Marine & Fire Insurance
- បរិញ្ញាបត្រផ្នែកពាណិជ្ជកម្មពី Sogang University, Seoul, Korea



### លោក Park, Cheon Gil
អភិបាល និងអគ្គនាយក

- ធ្លាប់កាន់តំណែងជា អគ្គនាយក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ Green Central
- ប្រធានគ្រប់គ្រងក្រុមហ៊ុន Samsung Card, Seoul, Korea
- ប្រធានក្រុមការងារក្រុមហ៊ុន Hyundai Card, Seoul, Korea
- នាយកនាយកដ្ឋានទីផ្សារនៃក្រុមហ៊ុន CJ Hello, Seoul, Korea
- វិញ្ញាបនប័ត្រផ្នែក Extension Marketing(2004) ពី UC Berkeley, California USA
- បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម Sogang University(1998), Seoul Korea
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម YONSEI University(2011), Seoul Korea

# គណៈគ្រប់គ្រង



### លោក ចេង ប៊ុនធឿន
នាយកប្រតិបត្តិការ

- ១៣ ឆ្នាំ មានបទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុ
- បានចាប់ផ្តើមអាជីពរបស់គាត់ពីមន្ត្រីឥណទាន មន្ត្រីត្រួតពិនិត្យឥណទាន អនុប្រធានផ្នែកផ្តល់ប្រាក់កម្ចី អ្នកគ្រប់គ្រងផ្នែកគ្រប់គ្រងហានិភ័យ នាយករងប្រតិបត្តិ នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន នាយកនាយកដ្ឋានគ្រប់គ្រងហានិភ័យ និងការអនុលោមភាព និងជានាយកប្រតិបត្តិការ
- គាត់បានបញ្ចប់បរិញ្ញាបត្រផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច (២០០៧) និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលសាធារណៈ (២០១៦)



### លោក Kim Keongu
ប្រធាននាយក នាយកដ្ឋានផែនការ

- បទពិសោធន៍ការងារជាង ១៤ឆ្នាំ ផ្នែកគណនេយ្យ (ប្រទេសកូរ៉េខាងត្បូង និងអាស៊ីអាគ្នេយ៍ មជ្ឈិមបូព៌ា)
- ធ្លាប់កាន់តំណែងជាប្រធានផ្នែកហិរញ្ញវត្ថុនៅ Hanshin Engineering and Construction Co., Ltd
- បរិញ្ញាបត្រផ្នែកគណនេយ្យនិងប្រព័ន្ធព័ត៌មាន (២០០៧)



### លោក ហំ សំណាង
ប្រធាននាយក នាយកដ្ឋាន ព័ត៌មានវិទ្យា និងអភិវឌ្ឍន៍ផលិតផល

- បានចូលបម្រើការងារនៅ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ឆ្នាំ ២០១៩ ជាអនុប្រធានផ្នែកព័ត៌មានវិទ្យា
- បទពិសោធន៍ការងារជាង ៥ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និង ៦ឆ្នាំនៅក្នុងវិស័យឯកជន
- ធ្លាប់កាន់តំណែងជាអ្នកសរសេរកម្មវិធីព័ត៌មានវិទ្យា អ្នកអភិវឌ្ឍន៍កម្មវិធីជាន់ខ្ពស់ ប្រធានផ្នែកគាំទ្រអតិថិជន ប្រធានផ្នែកប្រព័ន្ធគ្រប់គ្រងព័ត៌មាន នាយករងនាយកដ្ឋានព័ត៌មានវិទ្យា
- បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ



## លោក លឹម រតនៈ
នាយក នាយកដ្ឋាន ប្រតិបត្តិការទី១

- បទពិសោធន៍ការងារជាង ១២ឆ្នាំ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ធ្លាប់កាន់តំណែងជា មន្ត្រីឥណទានប្រតិបត្តិករ មន្ត្រីឥណទាន ប្រធានក្រុម នាយកសាខា និង ប្រធានផ្នែកហានិភ័យឥណទាន
- បរិញ្ញាបត្រផ្នែកអភិវឌ្ឍន៍ជនបទ (២០១១)



## លោក អ៊ុន សេងទ្រឿ
នាយករង នាយកដ្ឋានសវនកម្មផ្ទៃក្នុង

- បានចូលបម្រើការងារនៅ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ក្នុងខែមិថុនា ឆ្នាំ ២០១៩ ជាអ្នកគ្រប់គ្រងអង្គភាពសវនកម្មផ្ទៃក្នុង
- ១០ ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (ជោគជ័យ & អម្រឹត)
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីឥណទានជាន់ខ្ពស់ មន្ត្រីសវនកម្មផ្ទៃក្នុង មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ និង ប្រធានក្រុមសវនកម្មផ្ទៃក្នុង
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារ (២០១៦)



## កញ្ញា ផៃ ចន្ថា
នាយិកា នាយកដ្ឋាននីតិកម្ម និងប្រតិបត្តិតាម

- បទពិសោធន៍ ១០ ឆ្នាំក្នុងវិស័យច្បាប់ផ្សេងៗ ដូចជា មន្ត្រីច្បាប់ សាស្ត្រាចារ្យក្រៅម៉ោងផ្នែកច្បាប់ ទីប្រឹក្សាច្បាប់ជាន់ខ្ពស់សម្រាប់ក្រុមហ៊ុនច្បាប់ ទីប្រឹក្សាច្បាប់ជាន់ខ្ពស់សម្រាប់ធនាគារ និងអ្នកគ្រប់គ្រងផ្នែកច្បាប់ និងអនុលោមភាពសម្រាប់ក្រុមហ៊ុនទូរគមនាគមន៍
- ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ច្បាប់សហប្រតិបត្តិការសេដ្ឋកិច្ចពីសាកលវិទ្យាល័យ **Jean Moulin Lyon 3**
- បរិញ្ញាបត្រច្បាប់ឯកជនបារាំងពីសាកលវិទ្យាល័យ **Lumiere Lyon 2** និងច្បាប់កម្ពុជាពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច



## លោក ផៃ សុខជា
នាយក នាយកដ្ឋានហានិភ័យឥណទាន

- បទពិសោធន៍ការងារជាង ១៣ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីត្រួតពិនិត្យផ្ទៃក្នុង មន្ត្រីសវនកម្មផ្ទៃក្នុង មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ ប្រធានក្រុមសវនកម្មផ្ទៃក្នុង នាយករងនាយកដ្ឋានសវនកម្មផ្ទៃក្នុង រហូតដល់នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ (២០២១)



## លោក ម៉ុន រស្មី
នាយក នាយកដ្ឋាន គ្រប់គ្រងទ្រព្យសម្បត្តិ

- បទពិសោធន៍ការងារជាង ១០ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជាមន្ត្រីឥណទាន មន្ត្រីរដ្ឋបាល មន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងប្រធានផ្នែករដ្ឋបាល
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ចពាណិជ្ជកម្ម (២០១៩)



## លោក ដួង សត្យា
នាយក នាយកដ្ឋាន ប្រតិបត្តិការទី២ និង នាយកដ្ឋានអាជីវកម្ម

- បទពិសោធន៍ការងារជាង១២ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីដោះស្រាយបំណុល គ្រូបង្វឹក នាយករងប្រចាំសាខា នាយកសាខាជាន់ខ្ពស់ ប្រធានផ្នែកឥណទាន និងដោះស្រាយបំណុល ប្រធានប្រចាំតំបន់
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពាណិជ្ជកម្ម (២០១៣)



## លោកស្រី ពេជ្រ សូរិយា

នាយិកា នាយកដ្ឋានហិរញ្ញវត្ថុ

- បានចូលរួមការងារជាមួយជោគជ័យ ក្នុងខែមិថុនា ឆ្នាំ២០១៨ ជាប្រធានផ្នែកគាំទ្រគណនេយ្យ
- បទពិសោធន៍ការងារជាង ៩ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា បេឡាធិការ ប្រធានក្រុមគណនេយ្យ និងមន្ត្រីគាំទ្រគណនេយ្យ
- បរិញ្ញាប័ត្រផ្នែកគណនេយ្យ (២០១២)
- កំពុងបន្តការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ



## លោក នៅ គីមឡាយ

នាយករង នាយកដ្ឋានផែនការ

- បានចូលរួមការងារជាមួយជោគជ័យ ក្នុងខែមេសា ឆ្នាំ២០២០ ជាប្រធានផ្នែករតនាភិបាល
- បទពិសោធន៍ការងារជាង ១១ឆ្នាំជាមួយមីក្រូហិរញ្ញវត្ថុប្រាសាក់ ៤ឆ្នាំ ជាមន្ត្រីឥណទាន ៤ឆ្នាំ ជាមន្ត្រីជាន់ខ្ពស់ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ និង ២ឆ្នាំជាមន្ត្រីជាន់ខ្ពស់ផ្នែករបាយការណ៍បទបញ្ញត្តិ
- កំពុងបន្តការសិក្សាផ្នែក ACCA
- បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុនិងធនាគារ (២០១០)



## លោក ឈូ សុខលាភ

នាយករង នាយកដ្ឋាន ដោះស្រាយបំណុល

- បទពិសោធន៍ការងារជាង ១២ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (ប្រ្គីន, វើលខម ហ្វាយនែន និងជោគជ័យ)
- ធ្លាប់កាន់តំណែងជាមន្ត្រីបម្រើសេវាអតិថិជន មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន ប្រធានសាខា និង ប្រធានផ្នែកសវនកម្មផ្ទៃក្នុង
- បរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារ



## លោក រ៉េត ហ៊ង

នាយករង នាយកដ្ឋាន ប្រតិបត្តិការទី២

- បទពិសោធន៍ការងារជាង ១០ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ចាប់ផ្តើមអាជីពពីមន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន ប្រធានសាខា អ្នកគ្រប់គ្រងតំបន់ នាយករងនាយកដ្ឋានប្រតិបត្តិការ
- ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពាណិជ្ជកម្ម (២០១៩)



## លោក ដួង ម៉ៃឃី

នាយករង នាយកដ្ឋានធនធានមនុស្ស

- បទពិសោធន៍ នៅក្នុងការគ្រប់គ្រងធនធានមនុស្សលើសពី ៧ឆ្នាំ មកពីវិស័យខុសៗគ្នាជាច្រើនដូចជា វិស័យដំណោះស្រាយបច្ចេកវិទ្យា ទូរគមនាគមន៍ លក់រាយ និងវិស័យអចលនទ្រព្យ
- ចាប់ផ្តើមអាជីពការងារចាប់ពីតួនាទីផ្នែកជំនួយការធនធានមនុស្ស រហូតដល់ប្រធានគ្រប់គ្រងផ្នែកធនធានមនុស្ស គ្រប់គ្រងនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស
- បានបញ្ចប់បរិញ្ញាប័ត្រផ្នែកភាសាអង់គ្លេសសម្រាប់ការបង្រៀន (២០១៣)

# ប្រភពទុនវិនិយោគ

Industrial Bank of Korea
KDB Bank
PPCBank
KB Kookmin Bank
Shinhan Bank

# ដៃគូសហការ

Wing
true money
HYUNDAI
CAMKO MOTOR COMPANY LTD
BONCAFÉ
CB INSURANCE
FORTE INSURANCE

# យើងមានមោទនភាពជាខ្លាំងក្នុងការក្លាយជាសមាជិកនៃ

EUROCHAM CAMBODIA
KOCHAM
Cambodia Microfinance Association



# សមិទ្ធផលអាជីវកម្ម ឆ្នាំ២០២១

## តារាងសង្ខេបលទ្ធផលឆ្នាំ ២០២១

ចំនួនគណនីអតិថិជន

សមតុល្យផលប័ត្រឥណទានសរុប
(គិតជាដុល្លារអាមេរិក)

(គិតត្រឹមខែ កុម្ភៈ ២០២២)




ទ្រព្យសកម្មសរុប
(គិតជាដុល្លារអាមេរិក)

(គិតត្រឹមខែ កុម្ភៈ ២០២២)



“ ជោគជ័យ ហ្វាយនែន មានសេចក្តីសោមនស្សរីករាយនិងកិត្តិយសជាក្រៃលែងដែលទទួលបានកម្រិតអនុលោមភាព **សារពើពន្ធប្រភេទ " មាស "** ពី អគ្គនាយកដ្ឋានពន្ធដារ ដែលមានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២០ ដល់ ២០២១ ”




# ផលិតផលឥណទាន

## ឥណទានទូទៅ

ប្រភេទកម្ចីដើម្បីគាំទ្រដល់លំហូរសាច់ប្រាក់នៃការចំណាយក្នុងគ្រួសារឬការវិនិយោគប្រភេទណាមួយ។ វាអាចត្រូវបានប្រើប្រាស់សម្រាប់ការទិញដី ជួសជុល ឬទិញផ្ទះ បើកដំណើរការ ឬពង្រីកអាជីវកម្ម និងការចំណាយចាំបាច់សម្រាប់គ្រួសារជាទីស្រឡាញ់របស់ពួកគេ។



| | |
|---|---|
| **ទំហំកម្ចី** | ធំជាង ១០.០០០ ដុល្លារ ដល់ ៣០.០០០ដុល្លារ |
| **រយៈពេលកម្ចី** | រហូតដល់ ៧២ខែ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល, ប្រាក់ដុល្លារអាមេរិក |
| **របៀបបង់សង** | បង់រំលស់ថេរ ,បង់រំលស់ថយចុះ, បង់ការប្រាក់រាល់ខែនិងប្រាក់ដើមតាមការចរចា |

## ឥណទានកសិកម្ម

គោលបំណងនៃការប្រើប្រាស់គឺដើម្បីផ្តល់ដើមទុនដល់អតិថិជនក្នុងការវិនិយោគលើគ្រាប់ពូជរុក្ខជាតិឧបករណ៍កសិកម្មធុន់ៗ ឬ ទិញដីសម្រាប់សកម្មភាពដាំដុះកសិកម្ម។

| | |
|---|---|
| **ទំហំកម្ចី** | រហូតដល់ ៣០.០០០ ដុល្លារ |
| **រយៈពេលកម្ចី** | រហូតដល់ ៧២ ខែ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល, ប្រាក់ដុល្លារអាមេរិក |
| **របៀបបង់សង** | បង់ប្រាក់ដើមនៅចុងវគ្គ និងការប្រាក់ប្រចាំខែ បង់ប្រាក់ដើមតាមដំណាក់កាល,បង់រំលស់ថយចុះ, បង់រំលស់ថេរ |



# ឥណទានទាន់ចិត្ត

កញ្ចប់នៃប្រភេទកម្ចីពិសេសមួយសម្រាប់តម្រូវការបន្ទាន់ក្នុងការប្រើប្រាស់ទូទៅសម្រាប់ខ្លួនឯងផ្ទាល់ឬក្រុមគ្រួសារ។សេវាកម្មនេះនឹងផ្តល់លំហូរសាច់ប្រាក់ងាយស្រួលនិងរហ័សទាន់ចិត្តដល់ដៃអតិថិជន។

| | |
|---|---|
| **ទំហំកម្ចី** | រហូតដល់ ១០.០០០ ដុល្លារអាមេរិក ឬ រូបិយប័ណ្ណសមមូល |
| **រយៈពេលកម្ចី** | រហូតដល់ ៦០ខែ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល, ប្រាក់ដុល្លារអាមេរិក |
| **របៀបបង់សង** | បង់រំលស់ថេរ, បង់រំលស់ថយចុះ |




# ឥណទានយានយន្ត

ដើម្បីនាំមកនូវការរស់នៅប្រកបដោយផាសុកភាពសម្រាប់ប្រជាពលរដ្ឋខ្មែរ ផលិតផលនេះត្រូវបានរចនាឡើងសម្រាប់ជាជំនួយថវិកាក្នុងការទិញយានជំនិះដែលសមនឹងជីវភាពរបស់ពួកគេជាមួយនឹងប្រាក់តម្កល់អប្បបរមា ១០ភាគរយ។



| | |
|---|---|
| **ទំហំកម្ចី** | ចាប់ពី ៥០០ ដុល្លារ ដល់ ១០០.០០០ ដុល្លារ |
| **រយៈពេលកម្ចី** | រហូតដល់ ៨៤ ខែ |
| **រូបិយប័ណ្ណ** | ប្រាក់ដុល្លារអាមេរិក, ប្រាក់រៀល |
| **របៀបបង់សង** | បង់រំលស់ថេរ |



# ឥណទានអេសអឹមអ៊ី

ឥណទាននេះត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលកំពុងស្វែងរកការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរួមមានផលិតផល សេវាកម្ម សិប្បកម្ម សំណង់ និង ផលិតផលជាច្រើនទៀត។

| | |
|---|---|
| **ទំហំកម្ចី** | ធំជាង ៣០.០០០ ដល់ ១៥០.០០០ដុល្លារអាមេរិក |
| **រយៈពេលកម្ចី** | រហូតដល់ ១២០ខែ |
| **រូបិយប័ណ្ណ** | ប្រាក់ដុល្លារអាមេរិក, ប្រាក់រៀល |
| **របៀបបង់សង** | បង់រំលស់ថេរ, បង់រំលស់ថយចុះ, បង់ការប្រាក់ប្រចាំខែ និងប្រាក់ដើមតាមការចរចា |



# ឥណទានក្រុមធានា

ផលិតផលប្រាក់កម្ចីដែលមានមូលដ្ឋានលើសហគមន៍នេះត្រូវបានបង្កើតឡើងដើម្បីផ្តោតលើម្ចាស់អាជីវកម្មខ្នាតតូច កម្មកររោងចក្រ មន្ត្រីរាជការ អ្នកដែលមានប្រាក់ចំណូលទៀតទាត់ និងតាមរដូវ។



| | |
|---|---|
| **ទំហំកម្ចី** | រហូតដល់ ៨.០០០.០០០ រៀល សម្រាប់សមាជិកម្នាក់ៗ |
| **រយៈពេលកម្ចី** | ចាប់ពី ០៦ ខែ ដល់ ៣៦ ខែ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល |
| **របៀបបង់សង** | បង់ប្រាក់ដើមនៅចុងវគ្គ និងការប្រាក់ប្រចាំខែ បង់ប្រាក់ដើមតាមដំណាក់កាល, បង់រំលស់ថយចុះ |

## ឥណទានកាតគ្រីយានយន្ត

ផលិតផលប្រាក់កម្ចីមួយនេះត្រូវបានបង្កើតឡើងសម្រាប់ផ្តល់ជូនប្រាក់កម្ចីទៅដល់ម្ចាស់យានយន្តដោយពួកគេគ្រាន់តែដាក់ប័ណ្ណសម្គាល់យានយន្ត (កាតគ្រី) ជាទ្រព្យធានាជាការស្រេចក្នុងការទទួលយកកម្ចី។

| | |
|---|---|
| **ទំហំកម្ចី** | ចាប់ពី ២៥០ ដុល្លារ ដល់ ៣០.០០០ ដុល្លារ |
| **រយៈពេលកម្ចី** | ចាប់ពី ០៦ ខែ ដល់ ៦០ ខែ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល, ប្រាក់ដុល្លារអាមេរិក |
| **របៀបបង់សង** | បង់រំលស់ថេរ |



## ឥណទានអេឡិចត្រូនិច

ដើម្បីបំពេញតំរូវការអ្នកប្រើប្រាស់ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិច ផលិតផលនេះ ត្រូវបានបង្កើតឡើងដោយមានការសហការគ្នារវាង ជោគជ័យនិងហាងលក់ទូរស័ព្ទឬ ហាងអេឡិចត្រូនិច។



| | |
|---|---|
| **ទំហំកម្ចី** | រហូតដល់ ១,០០០ ដុល្លារ ឬ រូបិយប័ណ្ណសមមូល |
| **រយៈពេលកម្ចី** | ចាប់ពី ០៦ខែ ដល់ ២៤ខែ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល, ប្រាក់ដុល្លារអាមេរិក |
| **របៀបបង់សង** | បង់រំលស់ថេរ |

## ឥណទានសង្គ្រោះបន្ទាន់

កម្ចីនេះក៏ត្រូវបានរចនាឡើងសម្រាប់ជួយសម្រួលដល់អតិថិជនដែលត្រូវការសាច់ប្រាក់ភ្លាមៗ ឬបន្ទាន់ ដើម្បីទ្រទ្រង់ការចំណាយ ដែលមិនបានរំពឹងទុកក្នុងករណីបន្ទាន់នៅក្នុងគ្រួសារ។

| | |
|---|---|
| **ទំហំកម្ចី** | ចាប់ពី ១០០ ដុល្លារ ដល់ ៥.០០០ ដុល្លារ |
| **រយៈពេលកម្ចី** | ចាប់ពី ០៦ ខែ ដល់ ២៤ ខែ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល, ប្រាក់ដុល្លារអាមេរិក |
| **របៀបបង់សង** | បង់រំលស់ថេរ, បង់រំលស់ថយចុះ |



## ឥណទានបង្វិលទុនអាជីវកម្ម

ឥណទានបង្វិលទុនអាជីវកម្មគឺជាផលិតផលឥណទានមួយប្រភេទដែលអតិថិជនអាចដកប្រាក់បានរហូតដល់កម្រិតកំណត់ឥណទាន និង រយៈពេលដែលបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងឥណទានជាមួយលក្ខខណ្ឌកម្ចីនៅក្នុងរយៈពេលដ៏ខ្លី។



| | |
|---|---|
| **ទំហំកម្ចី** | ចាប់ពី ៥.០០០ ដុល្លារ ដល់ ២៥០.០០០ ដុល្លារ |
| **រយៈពេលកម្ចី** | រហូតដល់ ៦០ ខែ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល, ប្រាក់ដុល្លារអាមេរិក |
| **របៀបបង់សង** | បង់រំលស់ថេរ, សងការប្រាក់ប្រចាំខែ និងប្រាក់ដើមតាមការចរចា, រំលស់ថយចុះ |

# ការិយាល័យសាខាប្រតិបត្តិការ







## ១. ការិយាល័យកណ្ដាល និងសាខាស្ទឹងមានជ័យ

ផ្ទះលេខ ៩-១១ ផ្លូវវេងស្រេង ភូមិដំណាក់ធំ៥ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ២៤៧ ៣៣៣




## ២. សាខាតាខ្មៅ

ផ្លូវលេខ១១៥ ភូមិព្រែកសំរោង ៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៤១៨ ៣៣៣




## ៣. សាខាសែនសុខ

ផ្ទះលេខប៉េ០១៥ មហាវិថីមិត្តភាពភ្នំពេញ-ហាណូយ(១០១៩) ភូមិប៉ាយាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៤៥៨ ៣៣៣




## ៤. សាខាថ្នល់ទទឹង

ផ្លូវជាតិលេខ៤ ភូមិព្រៃគុយ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៤៦២ ៣៣៣




## ៥. សាខាកំពង់ស្ពឺ

ភូមិអង្គសេរី សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៤៩៦ ៣៣៣




## ៦. សាខាជើងព្រៃ

ភូមិស្គន់ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៣២៩ ៣៣៣




## ៧. សាខាគងពិសី

ផ្លូវជាតិលេខ៣ ភូមិក្របីត្រាំ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ
លេខទូរស័ព្ទ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ២០៩ ៣៣៣




## ៨. សាខាកំពង់ត្រឡាច

ផ្លូវជាតិលេខ៥ ភូមិច្រករមៀត ឃុំឈូក ស ស្រុកកំពង់ត្រឡាច
ខេត្តកំពង់ឆ្នាំង
លេខទូរស័ព្ទ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៨៤២ ៣៣៣



## ៩. សាខាត្រាំកក់

ផ្លូវជាតិលេខ៣ ភូមិអង្គតាសោម ឃុំអង្គតាសោម ស្រុកត្រាំកក់
ខេត្តតាកែវ
លេខទូរស័ព្ទ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ២១៤ ៣៣៣

# ព្រឹត្តិការណ៍សង្ខេបឆ្នាំ២០២១



“ ពិធីបើកសម្ពោធសាខាថ្មីសាខាត្រាំកក់ ”

“ ជោគជ័យ ហ្វាយនែន ភីអិលស៊ី បានចាប់ដៃគូអាជីវកម្ម
ជាមួយ ប៊ុងកាហ្វេ ខេមបូឌា ”









“ សិក្ខាសាលាស្ដីពីលទ្ធផលការងារក្នុងឆ្នាំ ២០២១
និងផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០២២ ”









“ ដំណើរកម្សាន្តរបស់ថ្នាក់គ្រប់គ្រងក្នុងការអបអរសាទរ
នៃការសម្រេចបានប្រាក់កម្ចី ៤០លានដុល្លារ ”



“ ព្រឹត្តិការណ៍ប្រកួតបាល់ទាត់ជើងឯក ជោគជ័យ ហ្វាយនែន ឆ្នាំ២០២១”




“ សកម្មភាពផ្តល់អំណោយសប្បុរសធម៌ដល់អាជ្ញាធរ និង
ប្រជាពលរដ្ឋនៅសង្កាត់ស្ទឹងមានជ័យ ៣ ”

# ភាពជោគជ័យរបស់អតិថិជន





**លោកស៊ិន រ៉ាហ៊ូ**
(ម្ចាស់ត្រាក់ទ័រឈូសដី និងត្រាក់ទ័រច្រូតស្រូវ)

*ជាមួយទឹកមុខរួសរាយរាក់ទាក់ ប្រកបដោយទំនុកចិត្ត លោកស៊ិន រ៉ាហ៊ូបាននិយាយថា៖ "ការប្រើប្រាស់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន គឺជាការសម្រេចចិត្តដ៏ត្រឹមត្រូវដែលបានផ្លាស់ប្តូរខ្សែជីវិតរបស់ខ្ញុំ ជាមួយការជ្រោមជ្រែងផ្នែកហិរញ្ញវត្ថុនេះ ការរស់នៅប្រចាំថ្ងៃរបស់ខ្ញុំ និងគ្រួសារបានផ្លាស់ប្តូរមុខមាត់ ប្រសើរឡើងគួរជាទីមោទនៈ។"*

នៅក្នុងវ័យ៣៦ឆ្នាំ បងប្រុសរ៉ាហ៊ូ មានសម្បុរស្រអែម និងកម្ពស់ខ្ពស់ល្មម បានរៀបរាប់ប្រាប់ក្រុមការងារយើងខ្ញុំពីប្រវត្តិនៃការធ្វើអាជីវកម្មប្រកបដោយលទ្ធផលផ្លែផ្ការបស់គាត់ ដោយប្រើប្រាស់កម្ចីរបស់ជោគជ័យ។ បច្ចុប្បន្នបងប្រុសកំពុងរស់នៅជាមួយភរិយា និងកូនប្រុសអាយុ៧ខែ ដ៏គួរឲ្យស្រលាញ់របស់គាត់ប្រកបដោយសុភមង្គល នៅក្នុងភូមិរឃាស ឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។

មុនទទួលបានជោគជ័យដូចបច្ចុប្បន្ន បងប្រុសប្រកបរបរស៊ីឈ្នួលបើកត្រាក់ទ័រឈូសដីឲ្យគេបានប្រាក់ចំណូល ប្រមាណ១លានរៀលក្នុងមួយខែ។ ដោយសង្កេតឃើញឱកាសល្អនៅកំឡុងពេលធ្វើការឲ្យគេ រួមជាមួយនឹងការផ្តល់ប្រឹក្សាដ៏ល្អពីសំណាក់មន្ត្រីឥណទានរបស់ជោគជ័យ បងប្រុសបានសម្រេចចិត្តស្នើកម្ចីពីជោគជ័យចំនួន ៥ម៉ឺនដុល្លារ ដើម្បីចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរបស់គាត់ជាមួយនឹងត្រាក់ទ័រមួយគ្រឿង និងដីមួយប្លង់សម្រាប់លក់សម្ភារៈជួលជុលត្រាក់ទ័រ។

ជាមួយនឹងការខិតខំប្រឹងប្រែងបំពេញការងារដោយមិនខ្លាចនឿយហត់ និងស្របតាមតម្រូវការទីផ្សារជាក់ស្តែង បងប្រុសបានស្នើកម្ចីបន្ថែមពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ដើម្បីពង្រីកអាជីវកម្មរបស់គាត់ដោយទិញត្រាក់ទ័រច្រូតស្រូវមួយបន្ថែមទៀត ដែលការពង្រីកនេះធ្វើឲ្យគាត់រកចំណូលបានប្រហែល ៥,០០០ដុល្លារក្នុងមួយខែៗ។

នៅថ្ងៃអនាគត បងប្រុសមានគម្រោងនឹងពង្រីកអាជីវកម្មរបស់គាត់បន្ថែមទៀត ជាមួយនឹងការលក់សម្ភារៈសំណង់ និងទិញអាប៊ុលឈូសដីថែមមួយទៀត។ និយាយពីការណែនាំវិញ ជាមួយខ និងលក្ខខណ្ឌសមស្រប និងងាយស្រួល បងប្រុសនឹងមិនស្ទាក់ស្ទើរក្នុងការណែនាំ ជោគជ័យ ទៅកាន់បងប្អូន ញាតិមិត្តដែលត្រូវការកម្ចីឡើយ។





*ជាមួយទឹកមុខស្រស់ស្រាយ អ្នកស្រីសុង ស្រីមុំ បាននិយាយថា៖"ពីរ បីឆ្នាំមុន មានក្រុមមន្ត្រីឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន មួយក្រុមបានចុះមកធ្វើការផ្សព្វផ្សាយផលិតផលរបស់គេក្នុងភូមិរបស់ខ្ញុំ។ ដើមឡើយខ្ញុំមិនបានសម្រេចចិត្តស្នើសុំកម្ចីទេ ទាល់តែក្រុមគាត់ចុះមកធ្វើការផ្សព្វផ្សាយជាលើកទីពីរបានខ្ញុំសម្រេចចិត្តខ្ចី ដោយសារខ្ញុំមានគំនិត ចង់ពង្រីកអាជីវកម្មកាត់ដេររបស់ខ្ញុំ និងចិញ្ចឹមជ្រូក។ ខ្ញុំបានសម្រេចចិត្តត្រូវ ប្រាក់ចំណូលរបស់ខ្ញុំចាប់ផ្តើមកើនឡើងជាលំដាប់ បន្ទាប់ពីពេលនោះមក។"*

**អ្នកស្រីសុង ស្រីមុំ**
(ជាងកាត់ដេរ និងម្ចាស់កសិដ្ឋានចិញ្ចឹមជ្រូក)

ក្នុងវ័យ៤០ឆ្នាំ បងស្រីសុង ស្រីមុំ កំពុងរស់នៅក្នុង ភូមិតាំងឃ្លៃ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ជាមួយស្វាមី និងកូនស្រីពីរនាក់ ដោយប្រកបអាជីវកម្មកាត់ដេរ និងចិញ្ចឹមជ្រូកយ៉ាងសស្រាក់សស្រាំជាមួយលទ្ធផលយ៉ាងល្អប្រសើរ។

គាត់បានចាប់ផ្តើមអាជីវកម្មកាត់ដេររបស់គាត់តាំងពីទស្សវត្សន៍ឆ្នាំ ៩០ មកម្ល៉េះ ជាមួយនឹងការប្រើប្រាស់ម៉ាស៊ីនកាត់ដេរចំនួន ២គ្រឿង និងចិញ្ចឹមជ្រូកពីរទៅបីក្បាល។ មុនពេលគាត់សម្រេចប្រើប្រាស់កម្ចីរបស់ជោគជ័យ គាត់រកចំណូលបានប្រហែល១ទៅ២លានរៀលក្នុងមួយខែ។

សម្រាប់កម្ចីវគ្គដំបូងបងស្រីស្នើកម្ចី៤០លានរៀល តែបន្ទាប់ពីឃើញសក្តានុពលនៃការវិនិយោគរបស់គាត់មួយរយៈមក គាត់ក៏បានស្នើកម្ចីបន្ថែមទៀតចំនួន១០០លានរៀលក្នុងរយៈពេល ៦ឆ្នាំពីជោគជ័យ។

សព្វថ្ងៃបងស្រីមានម៉ាស៊ីនកាត់ដេរចំនួន ៥ គ្រឿង ជាមួយនឹងជ្រូកចំនួន ៦០ក្បាល នៅក្នុងកសិដ្ឋានរបស់គាត់ហើយគាត់អាចរកប្រាក់ចំណូលបានពី៤ ទៅ៥លានរៀលក្នុងមួយខែ។

នៅប៉ុន្មានឆ្នាំខាងមុខ បងស្រីមានគម្រោងនឹងពង្រីកអាជីវកម្មចិញ្ចឹមជ្រូករបស់គាត់ ជាមួយនឹងការពង្រីកអាជីវកម្មកាត់ដេររបស់គាត់ដោយគាត់នឹងទិញសម្ភារៈកាត់ដេរមួយឈុតតែម្តង ដើម្បីបំពេញតម្រូវការរបស់អតិថិជនដ៏ច្រើនរបស់គាត់ទាន់ពេលវេលា។ បន្ថែមពីនេះគាត់បានអះអាងថា គាត់នឹងណែនាំ ជោគជ័យ ទៅកាន់អ្នកដែលគាត់ស្គាល់នៅពេលដែលពួកគេត្រូវការ ព្រោះបុគ្គលិកជោគជ័យ រួសរាយរាក់ទាក់ និងពូកែយកអាសារគ្នាណាស់។

# របាយការណ៍ហិរញ្ញវត្ថុ




## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

**ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍នេះភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ("ក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។**

### អំពីក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ("ក្រុមហ៊ុន") ក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិតដែលបានបង្កើតនៅព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ 0000 ២៩៥២ ចុះនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាដើម្បីដំណើរការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦។

ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅផ្ទះលេខ ៩-១១ ផ្លូវ វេងស្រេង សង្កាត់ស្ទឹងមានជ័យ ខណ្ឌស្ទឹងមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

### សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់ជូននូវសេវាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពដល់សហគ្រិនធុនតូច និងមធ្យម និងគ្រួសារដែលមានប្រាក់ចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងស្ថានភាពនៃប្រតិបត្តិការរបស់ក្រុមហ៊ុននាកាលបរិច្ឆេទនោះ ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុចាប់ពីទំព័រទី ៥១ ដល់ទំព័រទី ៥៧។

ក្រុមប្រឹក្សាភិបាលពុំបានផ្តល់អនុសាសន៍ ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះឡើយ។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះ មានដូចតទៅ៖

| ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទតែងតាំង |
| --- | --- | --- |
| លោក Moon Kyu Choi | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ |
| លោក Cheon Gil Park | អភិបាល និងនាយកប្រតិបត្តិ | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ |
| លោក Jung Hoon Kim | អភិបាលឯករាជ្យ | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២១ ត្រូវបានធ្វើសវនកម្មដោយ ក្រុមហ៊ុនស្នងការគណនេយ្យ ប្រ៊ែន សនថុន (ខេមបូឌា) លីមីតធីត។

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

អនុលោមទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលពុំមានភាគកម្មនៃភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនេះទេ។

## ព្រឹត្តិការណ៍ក្រោយរបាយការណ៍

មិនមានការកែតម្រូវ ឬព្រឹត្តិការណ៍សំខាន់ៗណាមួយបានកើតឡើងនៅក្នុងអំឡុងការិយបរិច្ឆេទនៃការរាយការណ៍ និងការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវក្នុងការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់បង្ហាញនូវភាពត្រឹមត្រូវ ពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យ ដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យនិងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

(ខ) គោរពតាមតម្រូវការលាតត្រដាងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (**“CIFRS for SMEs”**) និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជាឬប្រសិនបើមានការប្រាសចាកណាមួយពីតម្រូវការទាំងនោះក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាមានការប្រាសចាកទាំងនេះត្រូវលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) រក្សាទុកកំណត់ត្រាគណនេយ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យប្រកបដោយប្រសិទ្ធិភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនអាចសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតបន្តទៀតបាន និង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព ចូលរួមលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗ ទាំងអស់ដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុនហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏មានទំនួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនហើយក៏ត្រូវចាត់វិធានការឱ្យសមស្រប ដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាល ធានាអះអាងថាក្រុមហ៊ុនបានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយកាណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន របាយកាណ៍លំហូរសាច់ប្រាក់ ព្រមទាំងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងយ៉ាងសមរម្យ និងបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាការិយបរិច្ឆេទ គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទ ដោយអនុលោម តាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យម និងសេចក្តីណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា។

ជំនួស ឱ្យក្រុមប្រឹក្សាភិបាល




**លោក Cheon Gil Park**
អភិបាល និងនាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគហ៊ុនិករបស់
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី

## មតិយោបល់

យើងបានធ្វើសវនកម្ម ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាការិយបរិច្ឆេទ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន របាយកាណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងសេចក្តីសង្ខេបទៅលើគោលការណ៍គណនេយ្យសំខាន់ៗ និងសេចក្តីពន្យល់ព័ត៌មានផ្សេងៗទៀត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុរួមទាំងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម (**"CIFRS for SMEs"**) រួមជាមួយសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

## មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករ ទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ។ យើងមានឯករាជ្យភាព ក្នុងការធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារ នៃវិជ្ជាជីវៈគណនេយ្យអន្តរជាតិស្តីពី "ក្រមសីលធម៌ របស់គណនេយ្យករជំនាញ" (រួមជាមួយនឹងស្តង់ដារឯករាជ្យភាពអន្តរជាតិ ដែលហៅកាត់ថា **"IESBA Code"** ព្រមទាំងតម្រូវការក្រមសីលធម៌ដទៃទៀត ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញការទទួលខុសត្រូវទៅតាមក្រមសីលធម៌ផ្សេងៗទៀត ស្របតាមតម្រូវការទាំងនោះ និងតាម **IESBA Code**។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មទាំងឡាយដែលយើងខ្ញុំទទួលបានគឺគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់ជូនជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិរបស់យើងខ្ញុំ។

## ព័ត៌មានផ្សេងទៀត

គណៈគ្រប់គ្រង មានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលក៏ប៉ុន្តែមិនរាប់បញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំដែលទទួលបានមុន កាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនិងរបាយការណ៍ប្រចាំឆ្នាំ ដែលត្រូវបានរំពឹងថាធ្វើឡើងបន្ទាប់ពីកាលបរិច្ឆេទនោះឡើយ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ។ យើងខ្ញុំមិនផ្តល់ការធានាក្នុងទម្រង់បែបណាមួយឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុយើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬទេ ឬចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបានពីការធ្វើសវនកម្មថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើ យោងតាមការងារដែលយើងបានអនុវត្តហើយយើងខ្ញុំសន្និដ្ឋានថាបើមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានការរាយការណ៍ខុសជាសារវន្តយើងខ្ញុំតម្រូវឱ្យរាយការណ៍អំពីបញ្ហាទាំងនោះទៅក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុន ព្រមទាំងឆ្លើយតបនឹងបញ្ហានោះដោយអនុលោមតាមតម្រូវការស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាលេខ៧២០(កែសម្រួលថ្មី)។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (**"CIFRS for SMEs"**) និងទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពក្រុមហ៊ុន ក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តរភាពការលាតត្រដាងប្រសិនជាមានបញ្ហា ទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពលុះត្រាតែ ក្រុមប្រឹក្សាភិបាលមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

## ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល ពុំមានលក្ខណៈខុសឆ្គងជាសារវន្ត បណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង បញ្ចេញមតិលើរបាយការណ៍របស់សវនករ ដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ការធានាអះអាងដែលសមហេតុផលគឺជាការធានាអះអាងកម្រិតខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញកំហុសខុសឆ្គងនៅពេលវាកើតឡើងនោះទេ។ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាយើងអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងការរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថា តើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំនិងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំគឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់ លើប្រសិទ្ធិភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។
- ធ្វើការវាយតម្លៃ ភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។
- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់ របស់ក្រុមប្រឹក្សាភិបាល លើមូលដ្ឋាននិរន្តរភាពគណនេយ្យផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌ ដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពបន្តនិរន្តរភាពរបស់ក្រុមហ៊ុន។ ប្រសិនបើយើងសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើងយើងតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ ដើម្បីទាញការយកចិត្តទុកដាក់ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវនឹងត្រូវបានផ្តល់។ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្ម របស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាពឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុន មិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។
- វាយតម្លៃការបង្ហាញទូទៅរចនាសម្ព័ន្ធ និង មាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានា ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានា ដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាល ទៅលើបញ្ហាផ្សេងៗ កំណត់វិសាលភាពនិងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗ មួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញអំឡុងពេលធ្វើសវនកម្ម។







នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២



# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៧៣.៥៧៧ | ២៩៩.៧៥៣ | ៥៥.៦១៦ | ២២៤.៩៦៧ |
| ប្រាក់បញ្ញើនិងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ២៧៧.៥៥២ | ១.១៣០.៧៤៧ | ១៧៨.០៤៧ | ៧២០.២០០ |
| ប្រាក់បញ្ញើ និងតម្កល់នៅធនាគារផ្សេងៗ | ៦៩៨.៦៩៤ | ២.៨៤៦.៤៧៩ | ១.៣៦០.២២៩ | ៥.៥០២.១២៦ |
| ឥណទានផ្តល់ជូនអតិថិជន | ៤៣.០៧៨.៤២៦ | ១៧៥.៥០១.៥០៨ | ៣១.២២៦.៤៩០ | ១២៦.៣១១.១៥២ |
| ទ្រព្យសកម្មផ្សេងៗ | ១៧៩.៨០២ | ៧៣២.៥១៣ | ១២៨.៩៧១ | ៥២១.៦៨៨ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៤១៩.៦២៩ | ១.៧០៩.៥៦៩ | ៤១៦.១៥៤ | ១.៦៨៣.៣៤៣ |
| ទ្រព្យសកម្មអរូបី | ២១៦.៨៤៥ | ៨៨៣.៤២៧ | ២៤៣.៨៦១ | ៩៨៦.៤១៨ |
| **ទ្រព្យសកម្មសរុប** | **៤៤.៩៤៤.៥២៥** | **១៨៣.១០៣.៩៩៦** | **៣៣.៦០៩.៣៦៨** | **១៣៥.៩៤៩.៨៩៤** |

| | | | | |
|---|---|---|---|---|
| **មូលធន** | | | | |
| ភាគហ៊ុនដើមទុន | ៥.៥០០.០០០ | ២២.១៩៩.០០០ | ៣.៥០០.០០០ | ១៤.០៦៣.០០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ៤៨៧.៤៦៤ | ១.៩៧៤.៤៨១ | ២៤៩.៧៣៤ | ១.០០៧.៣៩៥ |
| ប្រាក់ចំណេញរក្សាទុក | ១.០១៨.៨៧៦ | ៤.១៥៩.៦៣២ | ៣០៣.១០១ | ១.២៤៧.៨៥៨ |
| លម្អៀងនៃការប្តូររូបិយប័ណ្ណបង្គរ | - | ២១០.៧១៨ | - | ៧៥.៤៦៥ |
| **មូលធនសរុប** | **៧.០០៦.៣៤០** | **២៨.៥៤៣.៨៣១** | **៤.០៥២.៨៣៥** | **១៦.៣៩៣.៧១៨** |

| | | | | |
|---|---|---|---|---|
| **បំណុល** | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវទូទាត់ផ្សេងៗ | ៤៨៥.៤៩០ | ១.៩៧៧.៨៨៦ | ២៨៣.៩២៦ | ១.១៤៨.៤៨១ |
| កម្ចីរយៈពេលខ្លី | ១៥.៧២៦.៨១៥ | ៦៤.០៧១.០៤៤ | ១៣.៧៤២.០៩៥ | ៥៥.៥៨៦.៧៧៤ |
| កម្ចីរយៈពេលវែង | ២១.៥១៩.១៤៦ | ៨៧.៦៦៩.០០១ | ១៥.៥០០.០០០ | ៦២.៦៩៧.៥០០ |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | ២០៦.៧៣៤ | ៨៤២.២៣៤ | ៣០.៥១២ | ១២៣.៤២១ |
| **បំណុលសរុប** | **៣៧.៩៣៨.១៨៥** | **១៥៤.៥៦០.១៦៥** | **២៩.៥៥៦.៥៣៣** | **១១៩.៥៥៦.១៧៦** |
| **មូលធន និងបំណុលសរុប** | **៤៤.៩៤៤.៥២៥** | **១៨៣.១០៣.៩៩៦** | **៣៣.៦០៩.៣៦៨** | **១៣៥.៩៤៩.៨៩៤** |

# របាយការណ៍ចំណូលលម្អិត

| | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ៦.១៦៥.៨៦២ | ២៥.០៨២.៧២៧ | ៤.២៥៩.៤៨០ | ១៧.៣៦៥.៩០០ |
| ចំណាយការប្រាក់ | (១.៧៧៣.៣០៥) | (៧.២១៣.៨០៥) | (១.២៨២.៣៩០) | (៥.២២៨.៣០៤) |
| **ចំណូលការប្រាក់សុទ្ធ** | **៤.៣៩២.៥៥៧** | **១៧.៨៦៨.៩២២** | **២.៩៧៧.០៩០** | **១២.១៣៧.៥៩៦** |
| ប្រាក់ចំណូលផ្សេងៗ | ៨៨.៨៧៩ | ៣៦១.៥៦០ | ៦៦.៨៩១ | ២៧២.៧១៥ |
| ចំណាយទូទៅ និងរដ្ឋបាល | (៣.២៥០.៥៨០) | (១៣.២២៣.៣៥៩) | (២.៤៧៣.៧៦៤) | (១០.០៨៥.៥៣៦) |
| សំវិធានធនសម្រាប់ឥណទានបាត់បង់និងជាប់សង្ស័យ | (១៣.១០៩) | (៥៣.៣២៧) | (៦៩.៥០៥) | (២៨៣.៣៧២) |
| **ប្រាក់ចំណូលមុនបង់ពន្ធ** | **១.២១៧.៧៤៧** | **៤.៩៥៣.៧៩៦** | **៥០០.៧១២** | **២.០៤១.៤០៣** |
| ចំណាយពន្ធលើប្រាក់ចំណូល | (២៦៤.២៤២) | (១.០៧៤.៩៣៦) | (១១៣.៦៧២) | (៤៦៣.៤៤១) |
| **ប្រាក់ចំណូលសុទ្ធក្នុងការិយបរិច្ឆេទ** | **៩៥៣.៥០៥** | **៣.៨៧៨.៨៦០** | **៣៨៧.០៤០** | **១.៥៧៧.៩៦២** |
| ចំណូលលម្អិតផ្សេងៗ | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ១៣៥.២៥៣ | - | (១២២.៣៦០) |
| **ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **៩៥៣.៥០៥** | **៤.១១៤.១១៣** | **៣៨៧.០៤០** | **១.៤៥៥.៦០២** |

# របាយការណ៍បម្រែបម្រួលមូលធន

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | ដើមទុនសរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ៣.៥០០.០០០ | ១៤.០៦៣.០០០ | ២៤៩.៧៣៤ | ១.០០៧.៣៩៥ | ៣០៣.១០១ | ១.២៤៧.៨៥៨ | ៧៥.៤៦៥ | ៤.០៥២.៨៣៥ | ១៦.៣៩៣.៧១៨ |
| ដើមទុនបន្ថែម | ២.០០០.០០០ | ៨.១៣៦.០០០ | - | - | - | - | - | ២.០០០.០០០ | ៨.១៣៦.០០០ |
| ចំណេញក្នុងគ្រា | - | - | - | - | ៩៥៣.៥០៥ | ៣.៨៧៨.៨៦០ | - | ៩៥៣.៥០៥ | ៣.៨៧៨.៨៦០ |
| ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | ២៣៧.៧៣០ | ៩៦៧.០៨៦ | (២៣៧.៧៣០) | (៩៦៧.០៨៦) | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | ១៣៥.២៥៣ | - | ១៣៥.២៥៣ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **៥.៥០០.០០០** | **២២.១៩៩.០០០** | **៤៨៧.៤៦៤** | **១.៩៧៤.៤៨១** | **១.០១៨.៨៧៦** | **៤.១៥៩.៦៣២** | **២១០.៧១៨** | **៧.០០៦.៣៤០** | **២៨.៥៤៣.៨៣១** |

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | ដើមទុនសរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ៣.៥០០.០០០ | ១៤.០៦៣.០០០ | ៣៨៨.៥៧៤ | ១.៥៧៣.៤៤៦ | (២២២.៧៧៩) | (៨៩៦.១៥៥) | ១៩៧.៨២៥ | ៣.៦៦៥.៧៩៥ | ១៤.៩៣៨.១១៦ |
| ចំណេញក្នុងគ្រា | - | - | - | - | ៣៨៧.០៤០ | ១.៥៧៧.៩៦២ | - | ៣៨៧.០៤០ | ១.៥៧៧.៩៦២ |
| ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (១៣៨.៨៤០) | (៥៦៦.០៥១) | ១៣៨.៨៤០ | ៥៦៦.០៥១ | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | (១២២.៣៦០) | - | (១២២.៣៦០) |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **៣.៥០០.០០០** | **១៤.០៦៣.០០០** | **២៤៩.៧៣៤** | **១.០០៧.៣៩៥** | **៣០៣.១០១** | **១.២៤៧.៨៥៨** | **៧៥.៤៦៥** | **៤.០៥២.៨៣៥** | **១៦.៣៩៣.៧១៨** |

# របាយការណ៍លំហូរសាច់ប្រាក់

| | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញមុនបង់ពន្ធ | ១.២១៧.៧៤៧ | ៤.៩៥៣.៧៩៦ | ៥០០.៧១២ | ២.០៤១.៤០៣ |
| **និយ័តកម្មសម្រាប់៖** | | | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១៥៩.១០៦ | ៦៤៧.២៤៣ | ១៤៣.៧០៧ | ៥៨៥.៨៩៣ |
| រំលស់ទ្រព្យអរូបី | ២៧.០១៦ | ១០៩.៩០១ | ១៥.៧៩៧ | ៦៤.៤០៤ |
| សំវិធានធនសម្រាប់ឥណទានបាត់បង់ និងជាប់សង្ស័យ | ១៣.១០៩ | ៥៣.៣២៧ | ៦៩.៥០៥ | ២៨៣.៣៧២ |
| ទ្រព្យសម្បត្តិ និងបរិក្ខាដែលលុបចោល | ៣៣៥ | ១.៣៦៣ | - | - |
| **ប្រតិបត្តិការចំណេញមុនបម្រែបម្រួលទុនបង្វិល** | ១.៤១៧.៣១៣ | ៥.៧៦៥.៦៣០ | ៧២៩.៧២១ | ២.៩៧៥.០៧២ |
| **បម្រែបម្រួលក្នុង៖** | | | | |
| ប្រាក់តម្កល់ធានាលើដើមទុន | (១00.000) | (៤០៦.៨០០) | - | - |
| ប្រាក់បញ្ញើមានកំណត់ | - | - | ១.៤០០.០០០ | ៥.៧០៧.៨០០ |
| ឥណទានផ្តល់ជូនអតិថិជន | (១១.៨៦៥.០៤៥) | (៤៨.២៦៧.០០៣) | (៩.៧៥៨.៥០៤) | (៣៩.៧៨៥.៤២១) |
| ទ្រព្យសកម្មផ្សេងៗ | (៦៦.១១១) | (២៦៨.៩៤០) | (៦៧.០៤០) | (២៧៣.៣២២) |
| បំណុលផ្សេងៗ | ២០១.៥៦៤ | ៨១៩.៩៦២ | (១១៧.៣០៩) | (៤៧៨.២៦៩) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ** | (១០.៤១២.២៧៩) | (៤២.៣៥៧.១៥១) | (៧.៨១៣.១៣២) | (៣១.៨៥៤.១៤០) |
| ពន្ធលើប្រាក់ចំណូលដែលត្រូវបង់ | (៨៨.០២០) | (៣៥៨.០៦៥) | (១១៤.៨៥៧) | (៤៦៨.២៧២) |
| **សាច់ប្រាក់សុទ្ធប្រើនៅក្នុងសកម្មភាពប្រតិបត្តិ** | **(១០.៥០០.២៩៩)** | **(៤២.៧១៥.២១៦)** | **(៧.៩២៧.៩៨៩)** | **(៣២.៣២២.៤១២)** |



| | | | | |
|---|---|---|---|---|
| **សកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យសកម្ម និងបរិក្ខារ | (១៦២.៩១៦) | (៦៦២.៧៤២) | (១៩៩.១៧១) | (៨១២.០២០) |
| ការទិញទ្រព្យអរូបី | - | - | (១៥៧.០៨០) | (៦៤០.៤១៥) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | **(១៦២.៩១៦)** | **(៦៦២.៧៤២)** | **(៣៥៦.២៥១)** | **(១.៤៥២.៤៣៥)** |
| | | | | |
| **សកម្មភាពហិរញ្ញប្បទាន** | | | | |
| ចំណូលពីប្រាក់កម្ចី | ៨.៩១៩.១៤៦ | ៣៦.២៨៣.០៨៦ | ១២.២៥៨.៣២៥ | ៤៩.៩៧៧.១៩១ |
| ដើមទុនបន្ថែម | ១.១០០.០០០ | ៤.៤៧៤.៨០០ | - | - |
| ការទូទាត់សងប្រាក់កម្ចី | - | - | (៣.២៥០.០០០) | (១៣.២៥០.២៥០) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន** | **១០.០១៩.១៤៦** | **៤០.៧៥៧.៨៨៦** | **៩.០០៨.៣២៥** | **៣៦.៧២៦.៩៤១** |
| | | | | |
| **បម្រែបម្រួលសាច់ប្រាក់និងសាច់ប្រាក់ សមមូលសុទ្ធ** | (៦៤៤.០៦៩) | (២.៦២០.០៧២) | ៧២៤.០៨៥ | ២.៩៥២.០៩៤ |
| សាច់ប្រាក់និងសាច់ប្រាក់សមមូលនាថ្ងៃទី១ ខែមករា | ១.៤១៨.៨៩២ | ៥.៧៧២.០៥៣ | ៦៩៤.៨០៧ | ២.៨៣១.៣៣៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៤.៦៤៨ | - | (៤៤.០១៥) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី៣១ ខែធ្នូ** | **៧៧៤.៨២៣** | **៣.១៥៦.៦២៩** | **១.៤១៨.៨៩២** | **៥.៧៣៩.៤១៨** |

# ការិយាល័យកណ្ដាល

ផ្ទះលេខ ៩-១១ ផ្លូវវេងស្រេង ភូមិដំណាក់ធំ៥
សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
គេហទំព័រ: www.chokchey.com.kh
អ៊ីមែល: info@chokchey.com.kh
ទូរស័ព្ទលេខ: ០២៣ ៩២២ ១២៦